# សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅឆ្នាំ២០២៤ របស់ក្រសួងផែនការ

## សមិទ្ធផល, បញ្ហាប្រឈម, ទិសដៅការងារ និងសំណូមពរ អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍

### ជា ចាន់ទុំ

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍

ទីស្តីការក្រសួងផែនការ, ថ្ងៃទី៨-៩ ខែមេសា ឆ្នាំ២០២៤

# មាតិកា

១)　ទិដ្ឋភាពទូទៅ

២)　សមិទ្ធផលការងារឆ្នាំ២០២៣

៣)　ការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច

៤)　បញ្ហាប្រឈម

៥)　ទិសដៅការងារឆ្នាំ២០២៤

៦)　សំណូមពរ

៧)　សន្និដ្ឋាន

# ១- ទិដ្ឋភាពទូទៅ ( ១ )

*"ប្រជាជនជាមធ្យោបាយសម្រាប់ការអភិវឌ្ឍផង និង គោលដៅចុងក្រោយនៃការអភិវឌ្ឍផង"*

*"Population is a Means and an End of Development"*

*"មិនទុកនរណាម្នាក់ស្ថិតនៅក្រៅការអភិវឌ្ឍ"*

*"Leaving No One Behind"*

# ១- ទិដ្ឋភាពទូទៅ (២)

ការងារស្នូលជាអាទិភាពរបស់អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍៖

- គោលនយោបាយជាតិប្រជាជន
- កម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល
- អភិវឌ្ឍន៍សហគមន៍,
- ការស្រាវជ្រាវនិងអភិវឌ្ឍន៍
- ការពិនិត្យតាមដាននិងការវាយតម្លៃ
- កិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យប្រជាជននិងអភិវឌ្ឍន៍។

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (១)

## គោលនយោបាយជាតិប្រជាជន (គ.ជ.ប.) ២០១៦-២០៣០

- **គ.ជ.ប.** ២០១៦-២០៣០ គឺឈរលើគោលការណ៍ *"ទទួលស្គាល់ និងគាំទ្រចំពោះសិទ្ធិរបស់គូស្វាមីភរិយានិងបុគ្គលទាំងអស់ ឱ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត ហើយឱ្យមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តនេះ"*។
- **គ.ជ.ប.** ២០១៦-២០៣០ ត្រូវបានរៀបចំជាផែនការសកម្មភាព ៥ដំណាក់កាល ដែលមួយដំណាក់កាលមានរយៈពេល៣ឆ្នាំដូចៗគ្នា។
- បច្ចុប្បន្ននេះ កំពុងអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ (២០២២-២០២៤)

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (២)
## កម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍

- បង្កើតយន្តការសម្របសម្រួលអន្តរស្ថាប័ន ដើម្បីតាមដាននិងពន្លឿនការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍៖
  - ✓ គណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍ **(គ.អ.ស.អ.ប.អ.)** → អនុក្រឹត្យ និងសេចក្ដីសម្រេចរាជរដ្ឋាភិបាល
  - ✓ គណៈកម្មការអន្តរក្រសួងកម្រិតបច្ចេកទេស នៃ **គ.អ.ស.អ.ប.អ.** → សេចក្ដីសម្រេចរដ្ឋមន្ត្រីក្រសួងផែនការ
  - ✓ គណៈកម្មាធិការប្រជាជននិងអភិវឌ្ឍន៍រាជធានី ខេត្ត → សេចក្ដីសម្រេចរដ្ឋមន្ត្រីក្រសួងផែនការ និងសេចក្ដីសម្រេចអភិបាលរាជធានី ខេត្ត
- សេចក្ដីព្រាងចុងក្រោយក្របខណ្ឌយុទ្ធសាស្ត្រកម្មជានិងផែនការសកម្មភាព ២០២៤-២០៣០៖ តាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (៣)

## ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាល

- សិក្ខាសាលាស្តីពី "ការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា៖ កត្តាប្រជាជននិងការអភិវឌ្ឍ" ចំនួន២ដងសមាសភាពចូលរួមមាន ថ្នាក់ដឹកនាំក្រសួង មន្ទីរផែនការរាជធានី ខេត្តទាំង២៥ មន្ទីរពាក់ព័ន្ធក្នុងខេត្តរៀបចំ និងអ្នកមានចំណែកពាក់ព័ន្ធ សង្គមស៊ីវិល ព្រមទាំងនិស្សិតបណ្តាសាកលវិទ្យាល័យ សរុប៤៣០នាក់។
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "គោលនយោបាយជាតិប្រជាជននិងប្រជាសាស្ត្រ " ចំនួន២ដង ដោយរួមមានមន្ទីរផែនការចូលរួមសរុប២៥រាជធានី ខេត្ត និងមានអ្នកចូលរួមសរុប១២៥នាក់។

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (៤)
## អភិវឌ្ឍន៍សហគមន៍

- របាយការណ៍ជាតិស្តីពីប្រជាសាស្រ្ត និងសង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជាឆ្នាំ២០២២
- សហការជាមួយនឹងសម្ព័ន្ធជនជាតិដើមភាគតិចរៀបចំ "សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការប្រមូល ចងក្រង និងបង្កើតមូលដ្ឋានទិន្នន័យសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា"
- សហការជាមួយសម្ព័ន្ធជនជាតិដើមភាគតិច ចុះប្រមូលសាកល្បងទិន្នន័យសហគមន៍ជនជាតិដើមភាគតិចនៅខេត្តកំពង់ធំ ស្ទឹងត្រែង និង មណ្ឌលគិរី
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំការអភិវឌ្ឍសហគមន៍សំណង់លំនៅឋានបណ្តោះអាសន្ន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលទ្ធផលរបាយការណ៍ទិន្នន័យសហគមន៍ឆ្នាំ២០២២

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (៥)

## ការស្រាវជ្រាវនិងអភិវឌ្ឍន៍

- រៀបចំឯកសារណែនាំស្តីពីវិធីសាស្ត្ររៀបចំផែនការ គោលនយោបាយ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ
- វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្ររៀបចំផែនការ គោលនយោបាយ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ កម្រិតមូលដ្ឋានដល់មន្ត្រីថ្នាក់ខេត្តប្រមាណ ៩០នាក់។
- ស្ថានភាពភាគលាភប្រជាសាស្ត្រ និងភាគលាភយេនឌ័រនៅកម្ពុជាឆ្នាំ២០២១
- សង្ខេបគោលនយោបាយ ស្តីពីការទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពប្រជាសាស្ត្រដើម្បីសម្រេចបានភាគលាភប្រជាសាស្ត្រកម្ពុជា

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (៦)
## ការពិនិត្យតាមដាននិងការវាយតម្លៃ

- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ២០២២-២០២៤
- របាយការណ៍អំពីសមិទ្ធផលនិងវឌ្ឍនភាពក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ក្នុងសន្និសីទថ្នាក់តំបន់នៅទីក្រុងបាងកក ប្រទេសថៃ
- ការវាយតម្លៃស្តីពីអាត្លាសគោលនយោបាយពន្យារកំណើត សម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្នាំ២០២៣ (Contraception Policy ATLAS Asia-Pacific) នាសន្និសីទប្រជាជនអាស៊ី-ប៉ាស៊ីហ្វិកលើកទី៧ នៅទីក្រុងបាងកក, ១៥-១៧ វិច្ឆិកា ២០២៣ កម្ពុជាបានស្ថិតក្នុងលំដាប់ប្រទេសដែលបានអនុវត្តល្អប្រសើរ (Best Performing Country) ស្ថិតក្នុងលំដាប់កំពូលនៃតារាង (ចំណាត់ថ្នាក់លេខ១, ពិន្ទុ ៩០,១%) ក្នុងចំណោមប្រទេសជាង៤០នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

# ២- សមិទ្ធផលការងារឆ្នាំ២០២៣ (៧)

## កិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យប្រជាជននិងអភិវឌ្ឍន៍

- ដៃគូសហការជាមួយនឹងអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ រួមមាន UNFPA, East-west Management Institute (EWMI), និងសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា
- សហការជាមួយនឹង UNFPA រៀបចំទិវាប្រជាជនពិភពលោកលើកទី៣៤ ក្រោមប្រធានបទ "*ការបញ្ចេញអានុភាពនៃសមភាពយេនឌ័រ ៖ ការជ្រោងឡើងនូវសម្លេងស្រ្តីនិងក្មេងស្រី ដើម្បីបង្ហាញពីលទ្ធភាពគ្មានដែនកំណត់នៃពិភពលោកយើង*"
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានមេគង្គនៅឆ្នាំ២០២៣ ក្នុងនាមកម្ពុជាជាប្រធានប្តូរវេននៃវិទ្យាស្ថានមេគង្គ (Mekong Institution) សម្រាប់រយៈពេល ២ឆ្នាំ (សីហា ២០១៣- សីហា ២០២៥)

# ៣- ការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច

## Cambodia Preparatory LDC Graduation

ក- លក្ខខណ្ឌនៃការចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច

ខ- យន្តការសម្របសម្រួលស្ថាប័នសហប្រជាជាតិ

គ- យន្តការសម្របសម្រួលស្ថាប័នថ្នាក់ជាតិ

# ក- លក្ខខណ្ឌនៃការចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច (១)

- អង្គការសហប្រជាជាតិ បានចាត់ថ្នាក់ប្រទេសក្នុងពិភពលោកជាបួនក្រុម គឺ (១) ក្រុមប្រទេសអភិវឌ្ឍន៍ (២) ក្រុមប្រទេសដែលកំពុងមានសេដ្ឋកិច្ចជឿនលឿនឆ្ពោះទៅរកប្រទេសអភិវឌ្ឍន៍ (៣) ក្រុមប្រទេសកំពុងអភិវឌ្ឍ និង (៤) ក្រុមប្រទេសអភិវឌ្ឍតិចតួច
- កម្ពុជា ត្រូវបានចាត់បញ្ចូលជាក្រុមប្រទេសអភិវឌ្ឍតិចតួចនៅឆ្នាំ១៩៩១
- ប្រទេសអភិវឌ្ឍតិចតួចមួយ ដែលអាចចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចបាន លុះត្រាឆ្លងការពិនិត្យ៣ឆ្នាំម្តង (Triennial Review) ចំនួន២ដងជាប់ៗគ្នាដោយជោគជ័យ

# ក- លក្ខខណ្ឌនៃការចាកចេញពីចំណាត់ក្រុមប្រទេស អភិវឌ្ឍតិចតួច (២)

- លក្ខណៈវិនិច្ឆ័យចំនួន៣ សម្រាប់ការចាកចេញ៖
  - ១- ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ (Gross National Income Per Capita – GNI Per Capita) ត្រូវស្មើឬធំជាង ១ ២២២ដុល្លារអាមេរិក
  - ២- សន្ទស្សន៍ទ្រព្យធនមនុស្ស (Human Assets Index–HAI) ត្រូវស្មើឬធំជាង ៦៦ពិន្ទុ
  - ៣- សន្ទស្សន៍ងាយរងគ្រោះសេដ្ឋកិច្ចនិងបរិស្ថាន (Economic and Environment Vulnerable Index – EVI) ត្រូវស្មើឬតូចជាង ៣២ពិន្ទុ

# ក- លក្ខខណ្ឌនៃការចាកចេញពីចំណាត់ក្រុមប្រទេស អភិវឌ្ឍតិចតួច (៣)

- កម្ពុជាបំពេញបាននូវលក្ខណៈវិនិច្ឆ័យទាំង៣ជាលើកទី១នៅឆ្នាំ២០២១ គឺកម្ពុជាមាន៖
  - ១- ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ស្មើនឹង ១ ៣៧៧ដុល្លារអាមេរិក
  - ២- ពិន្ទុសន្ទស្សន៍ទ្រព្យធនមនុស្សស្មើនឹង ៧៤,៣
  - ៣- ពិន្ទុងាយរងគ្រោះសេដ្ឋកិច្ចនិងបរិស្ថានស្មើនឹង ៣០,៦
- កម្ពុជាបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យទាំង៣ ក្នុងការវាយតម្លៃបឋមលើកទី២សម្រាប់ឆ្នាំ ២០២៤៖
  - ១- ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ស្មើ ១ ៥៤៦ដុល្លារ ធំជាងតម្លៃកំណត់ ១ ៣០៦ដុល្លារ
  - ២- សន្ទស្សន៍ទ្រព្យធនមនុស្សស្មើ ៧៧,៧ ធំជាងតម្លៃកំណត់ ៦៦,០
  - ៣- សន្ទស្សន៍ងាយរងគ្រោះសេដ្ឋកិច្ចនិងបរិស្ថានស្មើ ២៣,៣ តូចជាងតម្លៃកំណត់ ៣២,០
- ការវាយតម្លៃលើកទី២នេះ មានរួមបញ្ចូលនូវការវាយតម្លៃអំពីភាពងាយរងហានិភ័យដោយសារការចាកចេញ និងសូចនាករបន្ថែមជាច្រើន

# ខ- យន្តការសម្របសម្រួលស្ថាប័នសហប្រជាជាតិ

- គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ (Committee for Development Policy – CDP)
- ថ្ងៃទី៤-៨ ខែមីនា ឆ្នាំ២០២៤ CDP បានសម្រេចឱ្យកម្ពុជាចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចក្នុងរយៈពេលប្រាំឆ្នាំតាមសំណើរបស់កម្ពុជា
- CDP បានផ្ញើសំណើទៅក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចសហប្រជាជាតិ (ECOSOC) ដើម្បីប្រជុំពិនិត្យនិងផ្តល់ការគាំទ្រ ដែលគ្រោងនឹងធ្វើនៅខែមិថុនា ឆ្នាំ២០២៤
- មហាសន្និបាតអង្គការសហប្រជាជាតិ គ្រោងនឹងដំណើរការនៅខែកញ្ញា ឆ្នាំ២០២៤។ ប្រសិនបើមហាសន្និបាតរបស់អង្គការសហប្រជាជាតិកត់ត្រា (Take Note) តាមសំណើរបស់ CDP និង ECOSOC នោះកម្ពុជានឹងចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចជាផ្លូវការនៅឆ្នាំ២០២៩

# គ- យន្តការសម្របសម្រួលស្ថាប័នថ្នាក់ជាតិ

- **គណៈកម្មាធិការជាតិសម្រាប់ការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច (គ.ច.ក.អ.ត.)** → សេចក្ដីសម្រេចលេខ៩៤ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២។ **គ.ច.ក.អ.ត.** មានសមាសភាពពីក្រសួង ស្ថាប័នចំនួន១៩ → សេចក្ដីសម្រេចលេខ១៣៦ សសរ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ បានកែសម្រួលសមាសភាព **គ.ច.ក.អ.ត.**
- គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង (នឹងបង្កើតក្នុងករណីចាំបាច់)
- **គ.ច.ក.អ.ត.** មានក្រុមការងារចំពោះកិច្ចក្រសួងផែនការសម្រាប់ការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច ជាលេខាធិការដ្ឋាន
- ក្នុងរយៈពេលនៃការត្រៀមចាកចេញនេះ កម្ពុជាត្រូវរៀបចំ **យុទ្ធសាស្ត្រអន្តរកាលដោយរលូន** (Smooth Transition Strategy) សម្រាប់អនុវត្តក្រោយការចាកចេញ។

# ៣- បញ្ហាប្រឈម

- ការទទួលបានធាតុចូលយឺតពីក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា និងផែនការសកម្មភាព៖ តាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- ការផ្លាស់ប្តូរសមាសភាពជនបង្គោលរបស់ក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន ក្នុងការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា និងផែនការសកម្មភាព៖ តាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- មន្ត្រីដែលមានជំនាញខាងសរសេរគោលនយោបាយមានតិច ហើយចំណេះដឹងក៏នៅមានកម្រិត
- មិនមានមន្ត្រីជំនាញខាងវិភាគស៊ីជម្រៅទិន្នន័យប្រជាសាស្ត្រ, ភាគលាភប្រជាសាស្ត្រ, ....
- មិនមានរចនាសម្ព័ន្ធជាលេខាធិការដ្ឋានសម្រាប់ជួយការងារអគ្គលេខាធិការដ្ឋានក្នុងការសម្របសម្រួលការងាររដ្ឋបាលទូទៅ, ទំនាក់ទំនង, របាយការណ៍ និងថវិកាកម្មវិធី

# ៤- ទិសដៅការងារឆ្នាំ២០២៤

- បញ្ចប់ក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា និងផែនការសកម្មភាព ២០២៤-២០៣០៖ តាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- រៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិគោលនយោបាយជាតិប្រជាជន (**គ.ជ.ប.**)
- រៀបចំផែនការសកម្មភាព (២០២៥-២០២៧) នៃ **គ.ជ.ប.**
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ២០២២-២០២៤ នៃ **គ.ជ.ប.**
- បន្តនីតិវិធីក្នុងការចុះប្រមូលទិន្នន័យសហគមន៍ជនជាតិដើមភាគតិចតាមខេត្តគោលដៅ
- អនុវត្តការងារជាប្រចាំ (រួមមាន ទិវាប្រជាជនពិភពលោកលើកទី៣៥, ការងារផ្សព្វផ្សាយ, បណ្តុះបណ្តាល, កិច្ចប្រជុំប្រចាំឆ្នាំជាមួយនឹងមន្ទីរផែនការរាជធានី ខេត្ត.....)
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានមេគង្គនៅឆ្នាំ២០២៤
- រៀបចំ**យុទ្ធសាស្ត្រអន្តរកាលដោយរលូន** សម្រាប់អនុវត្តក្រោយការចាកចេញពី LDC

# ៥-សំណូមពរ

- ត្រូវការមន្ត្រីជំនាញក្មេងៗ (៥-១០នាក់) ដែលមានសមត្ថភាពខាងស្រាវជ្រាវ, សរសេរគោលនយោបាយ និងវិភាគទិន្នន័យស៊ីជម្រៅ
- ជំនាញដែលត្រូវការ គឺផ្នែកប្រជាសាស្ត្រ, ស្ថិតិប្រជាសាស្ត្រ, គោលនយោបាយសាធារណៈ, សេដ្ឋកិច្ច, សេដ្ឋកិច្ចអភិវឌ្ឍន៍, វិទ្យាសាស្ត្រកុំព្យូទ័រ, អភិវឌ្ឍន៍សហគមន៍, ផែនការអភិវឌ្ឍន៍, ...
- បង្កើតលេខាធិការដ្ឋាននៅអគ្គលេខាធិការដ្ឋាន ដើម្បីជួយការងារអគ្គលេខាធិការក្នុងការសម្របសម្រួលការងាររដ្ឋបាលទូទៅ, ទំនាក់ទំនង, របាយការណ៍, រួមទាំងថវិកាកម្មវិធី
- សូមថ្នាក់ដឹកនាំគ្រប់អង្គភាព គ្រប់ថ្នាក់ដឹកនាំនយោបាយ យកបញ្ហាប្រឈមសំខាន់ៗដែលបានរកឃើញនៅក្នុងសន្និបាតនេះមកពិភាក្សារួមគ្នា ដើម្បីរកដំណោះស្រាយ និងកែលម្អ សំដៅចូលរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងបង្កើនប្រសិទ្ធភាពការងារ។

# ៦- សន្និដ្ឋាន

- សន្និបាតបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារ គឺមានសារៈសំខាន់ណាស់ ដើម្បីឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងតាមអង្គភាពនីមួយៗ ក្នុងការអនុវត្តតួនាទីនិងភារកិច្ច, ព្រមទាំងកំណត់បានបញ្ហាប្រឈមជាក់លាក់ សម្រាប់កែលម្អក្នុងការអនុវត្តការងារឆ្នាំបន្ទាប់
- បង្កើននិងពង្រឹងសាមគ្គីភាពផ្ទៃក្នុង, ពង្រឹងទំនាក់ទំនងអន្តរជំនាន់ (ឆ្លងជំនាន់) និងផ្សព្វផ្សាយពីសារៈសំខាន់នៃការងារវិស័យផែនការ, ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ ដល់ក្រសួង ស្ថាប័ននានា។




# សូមអរគុណ!

## Thank You!